# របាយការណ៍វឌ្ឍនភាព ស្តីពី
# លទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចប្រចាំឆ្នាំ ២០២២

## ផ្នែកទី-I៖ ព័ត៌មានជាមូលដ្ឋានរបស់ក្រុមហ៊ុន

១-ក្រុមហ៊ុនឈ្មោះ ៖ **ហ្គ្រេនឌីស ធីមប៊ើរ អិលធីឌី**

២-ក្រុមហ៊ុន ៖ ក្នុងស្រុក ☐ បរទេស ☒ បើមកពីប្រទេស ស្នើបញ្ជាក់៖ ដាណឺម៉ាក់

៣-ឈ្មោះអភិបាលក្រុមហ៊ុន ៖ លោក Timothy Andrew Fleming ជនជាតិនូវែលសេឡង់

៤-អាស័យដ្ឋានទំនាក់ទំនងក្រុមហ៊ុន៖ មាន ☒ គ្មាន ☐ បើមាន៖

៤.១-ទីស្នាក់ការនៅភ្នំពេញ ៖ ផ្ទះលេខ ៣៨ដេ ផ្លូវ ៤៩៤ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចម្ការមន ក្រុងភ្នំពេញ

៤.២-ទីស្នាក់ការនៅខេត្ត ៖ ភូមិដូង ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

៤.៣-ទីស្នាក់ការនៅទីតាំងដីសម្បទាន៖ ចំណុចនិយាមកា ............... XY (404498; 1269851) .........ភូមិ .................ដូង..................... ឃុំ ក្រាំងដីវ៉ាយ............ ស្រុក ........ភ្នំស្រួច.............................. ខេត្ត ............កំពង់ស្ពឺ.......................... ផ្ទៃដីទំហំ ៧ ៨៩៦,១១ ហិកតា ..................

៤.៤-បុគ្គលិកទំនាក់ទំនង ៖ ឈ្មោះ លោកស្រី ហុង លីណា តួនាទី ប្រធានប្រតិបត្តិ លេខទូរស័ព្ទ ០១៧ ៦៦៦ ៤៣៥ Email hong.lina@grandistimber.com

៥-កម្មវត្ថុវិនិយោគ ៖ បង្កើតកសិដ្ឋានដាំដើមឈើម៉ៃសាក់ និងសាងសង់រោងចក្រកែច្នៃ

៦-អនុបយោគ ៖

- បានអនុវត្តន៍រួចរាល់ ☒ (ស្នើផ្តល់ឯកសារ) ......................................................................................................................................
- កំពុងអនុវត្តន៍ ☐ (ស្នើបញ្ជាក់ដំណើរការ និងផ្តល់ឯកសារ) .......................................................................................................
- មិនបានអនុវត្តន៍ ☐ ហេតុអ្វី? ..........................................................................................................................................................

៧-ការចុះបញ្ជីដីរដ្ឋ ៖

- បានអនុវត្តន៍រួចរាល់ ☒ (ស្នើផ្តល់ឯកសារ) ......................................................................................................................................
- កំពុងអនុវត្តន៍ ☐ (ស្នើបញ្ជាក់ដំណើរការ និងផ្តល់ឯកសារ) .......................................................................................................
- មិនបានអនុវត្តន៍ ☐ ហេតុអ្វី? ..........................................................................................................................................................

៨-កិច្ចសន្យាវិនិយោគ ៖ មាន ☒ គ្មាន ☐

- កិច្ចសន្យាដើមចុះថ្ងៃទី .....៣១......... ខែ .ធ្នូ........... ឆ្នាំ .....២០០៩........ សម្រាប់រយៈពេល ....៧០...... ឆ្នាំ លើផ្ទៃដីទំហំ .....៩ ៨២០.............. ហិកតា ដើម្បីវិនិយោគដាំដំណាំ......ម៉ៃសាក់................ ជាមួយក្រសួង....កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ..........ឬខេត្ត.......................................................................
- កិច្ចសន្យាកែសម្រួល ចុះថ្ងៃទី ...០១..... ខែ .ធ្នូ......... ឆ្នាំ ...២០១៧......... ស្តីពីការកែសម្រួលកិច្ចសន្យាដើមជាមួយក្រសួង ..កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៩-ការប្តូរសមាសភាពភាគហ៊ុន ៖ មាន ☒ គ្មាន ☐ បើមាន ស្នើផ្តល់ឯកសារ ....................................................................................................................

៩.១-ដំណាក់កាលមុនចុះកិច្ចសន្យា៖ - ក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្ម តាមលិខិតលេខ ៦៤៨៣ ពណ.បចព ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០០៨ របស់ក្រសួងពាណិជ្ជកម្ម

- តាមលក្ខន្តិកៈចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨៖
  - លោក Mikkel Otbo Nielsen ជាប្រធានក្រុមប្រឹក្សាភិបាលមានភាគហ៊ុនចំនួន ០០ ភាគហ៊ុន
  - លោក Daniel Keye Mitchell Jr ជាអភិបាល មានភាគហ៊ុន ចំនួន ០០ ភាគហ៊ុន
- លិខិតលេខ. ១១៦/០០៤ កសក.លស ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ស្តីពីការឯកភាពជាគោលការណ៍ទទួលស្គាល់លោក Timothy Andrew Fleming ជាប្រធានក្រុមប្រឹក្សាភិបាលថ្មីរបស់ក្រុមហ៊ុនហ្គ្រេនឌីស ជីមបើរ អិលធីឌី ជំនួសលោក Mikkel Otbo Nielsen ជាប្រធានក្រុមប្រឹក្សាភិបាលចាស់ និងតម្កល់លក្ខន្តិកៈក្រុមហ៊ុន។

៩.២-ដំណាក់កាលចុះកិច្ចសន្យា៖ - នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ក្រុមហ៊ុន បានចុះកិច្ចសន្យា ជាមួយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលមាន លោក Daniel Keye Mitchell Jr ជានាយកប្រត្តិបត្តិក្រុមហ៊ុន។

៩.៣-ដំណាក់កាលក្រោយចុះកិច្ចសន្យា៖ - ក្រោយពីចុះកិច្ចសន្យា ក្រុមហ៊ុនមិនមានការផ្លាស់ប្តូរសមាសភាពភាគហ៊ុននោះទេ ប៉ុន្តែបានប្តូរសមាសភាពក្រុមប្រឹក្សាភិបាលពីលោក Mikkel Otbo Nielsen ជាប្រធានក្រុមប្រឹក្សាភិបាល ជំនួសដោយលោក Timothy Andrew Fleming ជាប្រធានក្រុម ប្រឹក្សាភិបាលថ្មី តាមលក្ខន្តិកៈចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០(លិខិតលេខ៦១៦/០០៤ កសក.លសចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

១០-ប្រាក់កក់ធានាកិច្ចសន្យា៖ បានបង់ ☒ មិនបានបង់ ☐ មិនបានបង់ច្រើនឆ្នាំ ☐ ចំនួន **៩ ៨២០០ ដុល្លារអាមេរិក** លេខវិក័យប័ត្រ ១២៣០៤៥ បង់ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១០

១១-ការឯកភាពលើផែនការមេ៖ មាន ☒ គ្មាន ☐

- ផែនការមេថ្មី៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុម័តរួចរាល់ តាមលិខិតលេខ ២០២៤ កសក ចុះ ថ្ងៃទី២៧ ខែកុម្ភៈឆ្នាំ២០២០ (ឯកភាពតាមលិខិតលេខ ៧៦២០/៤៨១ កសក. ន.ផ ចុះថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

– ផែនការមេចាស់៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុម័តរួចរាល់ តាមលិខិតលេខ ៣២៥៩/៣៣៦ កសក.រផ.ផក ចុះថ្ងៃទី០២ ខែ មិថុនា ឆ្នាំ ២០១០។

១២-ផែនការសកម្មភាពប្រចាំឆ្នាំ៖ មាន ☒ គ្មាន ☐ កំពុងដំណើរការ ☐ (ស្នើបញ្ជាក់ និងស្នើផ្តល់ឯកសារ)............................................................................................

១៣-របាយការណ៍(EIA)ពេញលេញ៖

- បានអនុវត្តន៍រួចរាល់ ☒ (ស្នើផ្តល់ឯកសារ)
- របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ ត្រូវក្រសួងបរិស្ថានអនុម័តរួចរាល់ តាមលិខិតលេខ ១៥៦២ សជណ.បស្ក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩។
- បានអនុវត្តរួចរាល់ ESIA បឋម មាន ☑៖ លិខិតលេខ ១៧២ ស.ជ.ណ ប.ស្ក ចុះថ្ងៃទី ១៧ ខែមិនា ឆ្នាំ២០១៤ របស់ក្រសួងបរិស្ថាន

១៤-ការធ្វើសារពើភ័ណ្ឌព្រៃឈើ ៖ មាន ☐ គ្មាន ☒ (បើមាន ស្នើផ្តល់ឯកសារ បើគ្មានស្នើបញ្ជាក់មូលហេតុ)..........................................................................

| ឆ្នាំ | អនុតំបន់ | ឈើហ៊ុបមូល (ម³) | | | | កូនឈើ (ដើម) | | | | អូស (ស្ទែរ) | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រណិត | លេខ១ | លេខ២ | លេខ៣ និងក្រៅលំដាប់ | ប្រណិត | លេខ១ | លេខ២ | លេខ៣ និងក្រៅលំដាប់ | | |
| ឆមាសទី១ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ឆមាស់ទី២ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| សរុប | | | | | | | | | | | |

១៥-ការដេញថ្លៃ / ពិគ្រោះថ្លៃឈើ និងបង់ថ្លៃសួយសារ-បុព្វលាភផល អនុផលព្រៃឈើ (ឈើឈរ)៖ មាន ☐ គ្មាន ☒បើមាន ស្នើផ្តល់ឯកសារ......................................

| ឆ្នាំ | អនុតំបន់ | សួយសារឈើហ៊ុបមូល | | សួយសារកូនឈើ | | សួយសារអូស | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | សរុប | បង់រួច | សរុប | បង់រួច | សរុប | បង់រួច | |
| ឆមាសទី១ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ឆមាស់ទី២ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| សរុប | | | | | | | | |

១៦-ការអនុញ្ញាតឲ្យឈូសឆាយ ៖ មាន ☒ គ្មាន ☐

១. លិខិតលេខ.១៨៨ កសក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើផ្ទៃដីទំហំ១២១២ ហិកតា ក្នុងអនុតំបន់ទី១៨, ១៩, ២០ និង ២២។

២. លិខិតលេខ.៤០១២/២៥៦ កសក.នផ.ផក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ លើផ្ទៃដីទំហំ ២០០០ ហិកតា ក្នុងអនុតំបន់ទី ១៦ ១៧ និង ១៨។

៣. លិខិតលេខ. ៣២៥៩/៣៣៦ កសក.នផ.ផក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើផ្ទៃដីទំហំ ៤០៧ ហិកតា ក្នុងអនុតំបន់ទី១, ២, ១១, ១៦, ១៧, ២១, និង ២៣។

១៧-ការបង់ថ្លៃឈ្នួលដីសម្បទាន ៖

- ថ្លៃជួលដីសម្រាប់ឆ្នាំ ២០២១ (២០២១-២០២២) មិនទាន់បានបង់នៅឡើយ ដោយសារមិនទាន់ទទួលបានលិខិតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបញ្ជាក់ពីចំនួនទឹកប្រាក់សរុបដែលត្រូវបង់។
- បានបង់រួចសម្រាប់ឆ្នាំ២០២០ (២០២០-២០២១) នូវទឹកប្រាក់ចំនួន ៤១៤៩៤,៤៤ ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី
- បានបង់រួចសម្រាប់ឆ្នាំ២០១៩ (២០១៩-២០២០) នូវទឹកប្រាក់សរុបចំនួន ៤១០៨៣,៦១ ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី
- បានបង់រួចសម្រាប់ឆ្នាំ២០១៨ (២០១៨-២០១៩) នូវទឹកប្រាក់សរុបចំនួន ៤០៦៧៦,៨៦ ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី
- បានបង់រួចសម្រាប់ឆ្នាំ២០១៧ (២០១៧-២០១៨) នូវទឹកប្រាក់សរុបចំនួន ៤០២៧៤,១០ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី
- បានបង់រួចសម្រាប់ឆ្នាំ២០១៥ និង២០១៦ (២០១៤-២០១៥ និង២០១៥-២០១៦) នូវទឹកប្រាក់សរុបចំនួន ៧៩ ៣៥៥,៩០ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារកាណាឌីយ៉ា ក.អ កម្ពុជា

## ផ្នែកទី-II៖ ផែនការប្រើប្រាស់ដី និងវឌ្ឍនភាពនៃការអនុវត្តកិច្ចសន្យា និងផែនការមេ របស់គម្រោងវិនិយោគ

១-ផែនការប្រើប្រាស់ដីក្នុងផែនការមេ (ហិកតា)

| ឆ្នាំ | អនុតំបន់ | ផ្ទៃដីអាជីវកម្ម ផលិតកម្ម (ហ.ត) | ផ្ទៃដីផលិតកម្ម (ហ.ត) | ហេដ្ឋារចនាសម្ព័ន្ធ (ហ.ត) | ផ្ទៃដីតំបន់រក្សាទុក (ហ.ត) |
|---|---|---|---|---|---|
| ២០១០ ដល់ ២០១៩ | I-XXIII | ៤៦២៣ | ៣៦៧១ | ១៣១ | ៨២១ |
| ២០២០ | I, XIX,XX, XII, XIV | ៦៦២ | ៥៥៤ | ២៤ | ៨៤ |
| ២០២១ | II, III, XXII , VII | ៧៩៧ | ៥៧៥ | ១៤ | ២០៨ |
| ២០២២ | IV, XV, XIII | ៦៧០ | ៥២៩ | ៤ | ១៣៧ |
| ២០២៣ | XI | ៦២២ | ៥៦១ | ៧ | ៥៤ |
| ២០២៤ | III , XIV, XVI, XVIII | ៥២២ | ៥២២ | 0 | 0 |
| **សរុប** | | **៧៨៩៦** | **៦៤១២** | **១៨០** | **១៣០៤** |

២-ផែនការប្រើប្រាស់ដីក្នុងឆ្នាំ (ហិកតា)

| ឆ្នាំ | អនុតំបន់ | ផ្ទៃដីអាជីវកម្ម-ផលិតកម្ម (ហ.ត) | ផ្ទៃដីអនុញ្ញាត (ហ.ត) | ផ្ទៃដីអនុវត្តបាន (ហ.ត) | | | | ផ្ទៃដីនៅសល់ (ហ.ត) | មូលហេតុ |
|---|---|---|---|---|---|---|---|---|---|
| | | | | ប្រភេទដំណាំ | ផ្ទៃដីឈូសឆាយ | ផ្ទៃដីបានដាំដុះ | ដាំដុះឡើងវិញ | | |
| 2010 | 11 | 720.52 | 407.00 | ម៉ៃសាក់ | 105.91 | 30.30 | | 75.61 | |
| 2011 | 1,2,3,4,5,6,7,8,9,10,11,13,16 | 586.01 | | ម៉ៃសាក់ | 1,784.40 | 1,286.13 | | 498.27 | |
| 2012 | 3,12,13,14 | 904.70 | | ម៉ៃសាក់ និង ប្រភេទផ្សេងៗ | 1,482.63 | 381.80 | | 1,100.83 | |
| 2013 | 3,11,12,13,14,17,18,21 | 1,058.31 | 2,000.00 | ម៉ៃសាក់ និង ប្រភេទផ្សេងៗ | 974.56 | 1,626.38 | | (651.82) | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 2014 | 16,23 | 875.08 | | ម៉ែសាក់ និង ប្រភេទផ្សេងៗ | 1,367.58 | 496.35 | | 871.23 | |
| 2015 | 11,18,21 | 961.71 | | ម៉ែសាក់ និង ប្រភេទផ្សេងៗ | | 500.34 | | (500.34) | |
| 2016 | 14,17,21 | 328.64 | | ម៉ែសាក់ និង ប្រភេទផ្សេងៗ | | 500.89 | | (500.89) | |
| 2017 | 5,6,9,11,12,23 | 31.35 | | ម៉ែសាក់ និង ប្រភេទផ្សេងៗ | | | 111.68 | - | |
| 2018 | 5,7,8,11,12,13,20,22 | 570.88 | 1,212.00 | ម៉ែសាក់ និង ប្រភេទផ្សេងៗ | 441.75 | 214.61 | 39.08 | 227.14 | |
| 2019 | 11,13,20,22 | 374.80 | | ម៉ែសាក់ និង ប្រភេទផ្សេងៗ | | 85.29 | 12.20 | (85.29) | |
| 2020 | 16 | | | ម៉ែសាក់ និង ប្រភេទផ្សេងៗ | | 88.27 | 13.33 | (88.27) | |
| 2021 | គ្មានការដាំដុះ | គ្មានការដាំដុះ | គ្មានការដាំដុះ | គ្មានការដាំដុះ | គ្មានការដាំដុះ | គ្មានការដាំដុះ | គ្មានការដាំដុះ | គ្មានការដាំដុះ | |
| 2022 | | | | ប្រេងខ្យល់ | | ៣,១៦ | | | បន្ទាប់ពីដោះស្រាយទំនាស់ |
| **សរុប** | | **6,412.00** | **3,619.00** | | **6,156.83** | **5,213.52** | **176.29** | **946.47** | |

— ដាំដុះបាន ៤ ៦៧៦,៤៧ ហិកតាដំណាំម៉ៃសាក់

— ដាំដុះបាន ៣៦៩,៥០ ហិកតា ដំណាំអាកាស្យា

— ដាំដុះបាន ១០៨,៩៨ ហិកតា ដំណាំប្រេងខ្យល់

— ដាំដុះបាន ៤៧,០៩ ហិកតា ដំណាំគីនីន

— ដាំដុះបាន ១១,៤៨ហិកតា ដំណាំផ្សេងៗដែលយើងដាំដុះនៅលើផ្ទៃដីអាជីវកម្ម-ផលិតកម្ម។ ដំណាំផ្សេងសំដៅលើប្រភេទឈើប្រណិតដូចជាក្រញូង បេង គគីរ និងនាងនួន ។ ប្រភេទផ្សេងៗជាឈើប្រណិតនេះ បានដាំដុះលើផ្ទៃដីអាជីវកម្មដោយសារប្រភេទដីមិនសមបប្រកបសម្រាប់ដំនាំឈើពាណិជ្ជកម្ម។

៣-លទ្ធផលអនុវត្តន៍បាន

៣.១-ការប្រមូលសំណល់ឈើដែលបានពីការឈូសឆាយក្នុងអនុតំបន់នៃសម្បទានដីសេដ្ឋកិច្ច

| ឆ្នាំ | អនុតំបន់ | ឈើហ៊ុបមូល (ម$^{3}$) | | | | កូនឈើ (ដើម) | | | | អូស (ស្ទែរ) | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រណិត | លេខ១ | លេខ២ | លេខ៣ និងក្រៅលំដាប់ | ប្រណិត | លេខ១ | លេខ២ | លេខ៣ និងក្រៅលំដាប់ | | |
| ឆមាសទី១ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ឆមាស់ទី២ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| សរុប | | | | | | | | | | | |

បញ្ជាក់៖ ស្នើភ្ជាប់ផែនទីប្រមូលសំណល់ផលឈើ ដោយបញ្ជាក់ចំណុចនិយាមកាច្បាស់លាស់

៣.២-ការបង់ថ្លៃសួយសារ និងបុព្វលាភសំណល់ឈើដែលបានពីការឈូសឆាយក្នុងអនុតំបន់នៃសម្បទានដីសេដ្ឋកិច្ច

| ឆ្នាំ | អនុតំបន់ | សួយសារ និងបុព្វលាភឈើហ៊ុបមូល រៀល) | | | | សួយសារ និងបុព្វលាភកូនឈើ (រៀល) | | | | សួយសារ និងបុព្វលាភ អូស (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រណិត | លេខ១ | លេខ២ | លេខ៣ និងក្រៅលំដាប់ | ប្រណិត | លេខ១ | លេខ២ | លេខ៣ និងក្រៅលំដាប់ | | |
| ឆមាសទី១ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ឆមាស់ទី២ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| សរុប | | | | | | | | | | | |

៣.៣-លទ្ធផលអនុវត្តបានក្នុងឆ្នាំកន្លងមក

| ឆ្នាំ | អនុតំបន់ | ផ្ទៃដីអាជីវកម្ម | ផ្ទៃដីអនុញ្ញាត | លទ្ធផលអនុវត្តបាន | | | | មូលហេតុ |
|---|---|---|---|---|---|---|---|---|
| | | | | ប្រភេទដំណាំ | ផ្ទៃដីឈូសឆាយ | ផ្ទៃដីដាំដុះបាន | ផ្ទៃដីនៅសល់ | |
| ២០២១ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | កូវីដ ១៩ |
| សរុប | | | | | | | | |

៣.៤-លទ្ធផលអនុវត្តបានក្នុងឆ្នាំ..២០២២...........(ហិកតា)

| ឆ្នាំ | អនុតំបន់ | ផ្ទៃដីអាជីវកម្ម | ផ្ទៃដីអនុញ្ញាត | លទ្ធផលអនុវត្តបាន | | | | មូលហេតុ |
|---|---|---|---|---|---|---|---|---|
| | | | | ប្រភេទដំណាំ | ផ្ទៃដីឈូសឆាយ | ផ្ទៃដីដាំដុះបាន | ផ្ទៃដីនៅសល់ | |
| ឆមាសទី១ | | | | ប្រេងខ្យល់ | | ៣,១៦ | | ផ្ទៃដីដាំដុះបន្ទាប់ពីដោះស្រាយបញ្ហាដីធ្លីរួចរាល់ |
| ឆមាសទី២ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| សរុប | | | | | | | | |

៣.៤-ការប្រមូលផលដំណាំ

| ឆ្នាំ | អនុតំបន់ | ទំហំផ្ទៃដីដាំដុះ | ប្រភេទដំណាំ | ទិន្នផល/ហិកតា | ទិន្នផលសរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |

៤-ការប្រើប្រាស់ផល ឬផលិតផល

| ឆ្នាំ | ប្រភេទដំណាំ | បរិមាណផល ឬផលិតផលទទួលបាន | | បរិមាណផល ឬផលិតផលនាំចេញ | | បរិមាណផល ឬផលិតផលប្រើប្រាស់ក្នុងស្រុក | |
|---|---|---|---|---|---|---|---|
| | | ផល | ផលិតផល | ផល | ផលិតផល | ផល | ផលិតផល |
| គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |

៥-ការសាងសង់ក្នុងតំបន់សម្បទាន

| ល.រ | សំណង់ | ឆ្នាំ | | អនុតំបន់ | ទំហំសរុប | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ឆមាសទី១ | ឆមាសទី២ | | ឯកត្តា | ចំនួន | ទំហំ | |
| ១ | ជួសជុលផ្លូវក្នុងតំបន់ដីសម្បទាន | មាន | គ្មាន | | គ.ម | ៤ខ្សែ | ១០,១៩ | |

៦-ការប្រើប្រាស់កម្លាំងពលកម្ម

| ឆ្នាំ....២០២២ | កម្លាំងពលកម្ម | ចំនួន (នាក់) | ប្រាក់បៀវត្ស (នាក់/ខែ) | សម្ភារឧបត្ថម្ភបន្ថែម | ផ្សេងៗ |
|---|---|---|---|---|---|
| ឆមាសទី១ | បុគ្គលិកខ្មែរ | ៣៦ | ៦១២,៥៩ ដុល្លារ | | |
| | បុគ្គលិកបរទេស | គ្មាន | | | |
| | កម្មករខ្មែរអចិន្ត្រៃយ៍ | ២៨ | ១៨៣,២៨ ដុល្លារ | | |
| | កម្មករបរទេស | គ្មាន | | | |
| | កម្មករអណ្តែត | គ្មាន | | | |
| ឆមាសទី២ | បុគ្គលិកខ្មែរ | ៣៤ | ៦២១,៣២ ដុល្លារ | | |
| | បុគ្គលិកបរទេស | គ្មាន | | | |
| | កម្មករខ្មែរអចិន្ត្រៃយ៍ | ១១ | ១៩៤ ដុល្លារ | | |
| | កម្មករបរទេស | គ្មាន | | | |
| | កម្មករអណ្តែត | គ្មាន | | | |
| ប្រចាំឆ្នាំ | បុគ្គលិកខ្មែរ | ៣៥ | ៦១៧,០០ ដុល្លារ | | |
| | បុគ្គលិកបរទេស | គ្មាន | | | |
| | កម្មករខ្មែរអចិន្ត្រៃយ៍ | ១៩ | ១៨៨,៦៤ ដុល្លារ | | |
| | កម្មករបរទេស | គ្មាន | | | |
| | កម្មករអណ្តែត | គ្មាន | | | |

- តម្រូវការកម្លាំងពលកម្មអតិបរមាតាមរដូវកាល ជាពិសេសកំឡុងពេលដាំដុះ និងរដូវការពារភ្លើងព្រៃ ដែលនៅចន្លោះពីខែមករា ដល់ខែ សីហា។ ប៉ុន្តែក្រុមហ៊ុន ប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុមហ៊ុនបានធ្វើការផ្លាស់ប្តូរពីការជ្រើសរើសកំលាំងពលកម្មច្រើនក្នុងរដូវការដាំដុះ និងរដូវការពារភ្លើង បន្ថយមកចំនួនប្រហែលជា ១០០ នាក់ក្នុងរដូវកាលនេះ។ ការធ្វើបែបនេះបានជួយឱ្យប្រជាជនក្នុងសហគមន៍ទទួលបានការងារពេញមួយឆ្នាំ។
- ប្រភពកម្លាំងពលកម្មៈ ភាគច្រើន (៩០%) ជាអ្នកភូមិដែលរស់នៅជាប់ និងក្នុងសម្បទានដីសេដ្ឋកិច្ច។

**ផ្នែកទី-III៖ ការតវ៉ាទាមទារដីធ្លី ទំនាស់ដីធ្លី និងបទល្មើសព្រៃឈើ**

១-ការតវ៉ាទាមទារដីធ្លី ៖ មាន ☐ គ្មាន ☒ អនុតំបន់ ................... ផ្ទៃដីទំហំ ............. ហិកតា ចំណុចនិយាកា ....................................... ថ្ងៃខែឆ្នាំ .................... ដំណោះស្រាយ.......................................................................................................................................................................

២-ទំនាស់ដីធ្លី ៖ មាន ☒ គ្មាន ☐

- យោងតាមរបាយការណ៍ត្រីមាសទី៣ ឆ្នាំ២០២២ បញ្ហាសរុបទាំងអស់មានចំនួន ២៥៩ ករណី (១៤១ ករណីបានដោះស្រាយរួចរាល់ និង១១៨ ករណីកំពុងបន្តដោះស្រាយ)។
- សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២២ ត្រឹមពាក់កណ្តាលខែ ធ្នូ មិនមានបញ្ហាដីធ្លីថ្មី កើតឡើងនោះទេ។ ប៉ុន្តែក្រុមហ៊ុនបានធ្វើការដោះស្រាយបានបញ្ហាចំនួន ០៥ ករណីបន្ថែមទៀត។
- ដូចនេះបញ្ហាទំនាស់ដីធ្លីសរុបរហូតដល់ត្រីមាសទី៤ នៅឆ្នាំ២០២២ នេះមានចំនួន ២៥៩ ករណី (១៤៦ ករណីបានដោះស្រាយរួចរាល់ និង១១៣ ករណីកំពុងបន្តដោះស្រាយ)។
- ១១៣ ករណី (១៥៤,២២ ហិកតា) ដែលកំពុងបន្តដោះស្រាយរួមមាន៖
  - ៨៧ ករណី (១៤១,៨១ ហិកតា) នៃបញ្ហាសរុប ១០៧ករណីដែលកើតចេញពីការចុះបញ្ជីជាប្រព័ន្ធ នៅស្រុកឱរ៉ាល់
  - ០៣ ករណី (០,៨៧ ហិកតា) ជាបញ្ហាដែលកើតមានស្រាប់ មិនមែនចេញពីការចុះបញ្ជីជាប្រព័ន្ធ នៅស្រុកឱរ៉ាល់
  - ២៣ ករណី (១១,៥៤ ហិកតា) ជាបញ្ហាដែលកើតមានស្រាប់ នៅស្រុកភ្នំស្រួច។

**វិធានការដោះស្រាយ និងលទ្ធផល**

គិតត្រឹមត្រីមាសទី០៤ ឆ្នាំ២០២២ ក្រុមហ៊ុនបានខិតខំប្រឹងប្រែងធ្វើការដោះស្រាយ សម្របសម្រួលបញ្ហាមួយចំនួនតាមលទ្ធភាពដែលក្រុមហ៊ុនអាចធ្វើបាន។ ជាក់ស្តែងដូចដែលបានបង្ហាញខាងលើ ប៉ុន្តែស្របពេលជាមួយគ្នានោះដែរ បញ្ហាដីធ្លីថ្មីក៏បាននៅបន្តកើតឡើង។ សម្រាប់បញ្ហាដែលកំពុងបន្តដោះស្រាយទាំងបញ្ហាដែលកើតចេញពីការចុះបញ្ជីជាប្រព័ន្ធ និងមិនមែនកើតចេញពីការចុះបញ្ជីជាប្រព័ន្ធក្តីក្រុមហ៊ុនបានអនុវត្ត និងបន្តស្នើរសុំសមត្ថកិច្ចដែលពាក់ព័ន្ធដូចខាងក្រោម៖

- ដាក់បណ្តឹងទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងស្ថាប័នពាក់ព័ន្ធ ជំទាស់លើលទ្ធផលនៃវិនិច្ឆ័យក្បាលដីសម្រាប់ចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ, បានជួបប្រជុំជាមួយប្រធានក្រុមការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធថ្នាក់ស្រុកដើម្បីស្វែងយល់ពីបញ្ហា និងកំណត់ទិសដៅដោះស្រាយបន្ត និងបានកំណត់មុខសញ្ញាអ្នកទាមទារ ទីតាំងទាមទារ (ទំនាស់) និងផែនទី ដើម្បីមានមូលដ្ឋានក្នុងរាយការណ៍ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីមានអន្តរាគមន៍។ បន្ថែមលើនេះទៀត តាមរយៈរបាយការណ៍នៃកិច្ចប្រជុំក្រុមការងារអន្តរឃុំ (រស្មីសាមគ្គី និងក្រាំងដីវ៉ាយ) នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ បានផ្តល់អនុសាសន៍ដូចខាងក្រោម៖
  - ➢ បញ្ហាដីធ្លីដែលស្ថិតនៅលើដីរដ្ឋដែលប្រជាជនមូលដ្ឋានបានដាក់ស្នើសុំកាត់ឆ្វៀលតាមអនុសាសន៍ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាល ត្រូវរង់ចាំការសម្រេចពីរាជរដ្ឋាភិបាល
  - ➢ រៀបចំរបាយការណ៍ស្តីពីបញ្ហាដីធ្លីជាន់នឹងសម្បទានដីសេដ្ឋកិច្ចទាំងអស់ ជាពិសេសបញ្ហាដែលកើតចេញពីការត្រួតចុះបញ្ជីដីជាប្រព័ន្ធ គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត តាមរយៈរដ្ឋបាលស្រុកទាំងពីរដើម្បីស្នើសុំវិធានការដោះស្រាយ
  - ➢ នៅថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២១ ក្រុមហ៊ុនបានដាក់លិខិតគោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តតាមរយៈរដ្ឋបាលស្រុកឱរ៉ាល់ដើម្បីសុំអន្តរាគមន៍អំពីបញ្ហាដីធ្លីមានកើតមានក្នុងភូមិសាស្ត្រស្រុកឱរ៉ាល់។បច្ចុប្បន្នក្រុមហ៊ុនមិនទាន់ទទួលបានការឆ្លើយតបពីឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តនៅឡើយទេ។
  - ➢ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ ក្រុមហ៊ុនបានដាក់លិខិតគោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទដើម្បីស្នើរសុំកិច្ចអន្តរាគមន៍អំពីបញ្ហាដីធ្លី ក៏ដូចជាស្នើរសុំអោយក្រសួងចាត់វិធានការតាមនីតិវិធីច្បាប់ចំពោះបញ្ហាដីធ្លីដែលជាន់ប្លង់ជាមួយសម្បទានដីសេដ្ឋកិច្ចដែលបានចុះបញ្ជី និងធ្វើអនុបយោគរួចរាល់។ ប៉ុន្តែក្រុមហ៊ុនមិនទាន់ទទួលបានការឆ្លើយតបពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំពោះលិខិតនេះនៅឡើយទេ។
  - ➢ នៅថ្ងៃទី១១ ខែវិច្ឆកា ឆ្នាំ២០២១ ក្រុមហ៊ុនបានធ្វើរបាយការណ៍បច្ចុប្បន្នភាពស្តីពីបញ្ហាដីធ្លីទាំងអស់ដែលកើតមានឡើងជាន់ជាមួយសម្បទានដីសេដ្ឋកិច្ច ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីត្រួតពិនិត្យ និងសម្របសម្រួលក្នុងការដោះស្រាយលើបញ្ហាដីធ្លីទាំងអស់។ របាយការណ៍នេះត្រូវបានធ្វើឡើងដោយមានការផ្តល់យោបល់ពីលោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយយោងតាមស្មារតីអង្គប្រជុំនៅថ្ងៃ ០៨ ខែវិច្ឆិកា ឆ្នាំ២០២១ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ។ ប៉ុន្តែក្រុមហ៊ុនក៏មិនទទួលបានការសម្របសម្រួលពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទបន្ទាប់ពីធ្វើការរាយការណ៍នៅថ្ងៃទី ១១ វិច្ឆកា ឆ្នាំ២០២១។

៣-បទល្មើសព្រៃឈើ ៖ មាន ☒ គ្មាន ☐ អនុតំបន់ .................... ផ្ទៃដីទំហំ .............. ហិកតា ចំណុចនិយាកា ........................................ ថ្ងៃខែឆ្នាំ ....................

ដំណោះស្រាយ ........................................................................................................................................................

- ➢ សម្រាប់ត្រីមាសទី៤ នេះមានបទល្មើសព្រៃឈើជាច្រើនជាពិសេសការកាប់ឈើ ធ្វើអុសឡធ្យូង។ បទល្មើសនេះបានកើតមានទាំងក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច (តំបន់ការពារប្រភពទឹក និងដីដាំដុះអនាគត) និងតំបន់ស្ថានីយស្តារព្រៃឈើ ទាំងការកាប់ឈើអុសឡធ្យូង និងការទន្ទ្រានដីពីសំណាក់ជនមិនស្គាល់អត្តសញ្ញាណ។

➢ ក្រុមហ៊ុនបានធ្វើការរាយការណ៍ជូនមន្ទីរ និងស្នើសុំអន្តរាគមន៍សម្រាប់ការចុះបង្ក្រាបបទល្មើស។ ជាដំណោះស្រាយមន្ទីរបានចាត់ឱ្យមានមន្ត្រីប្រចាំការ ដើម្បីសហការជាមួយក្រុមហ៊ុនក្នុងការចូលរួមពង្រឹងការអនុវត្តច្បាប់រួមមានការអប់រំណែនាំ និងវិធានការផ្សេងទៀត។

**ផ្នែកទី-IV៖ ការកាត់ឆ្វៀលដី**

- តាមបទបញ្ជា០១៖ មាន ☒ គ្មាន ☐ ផ្ទៃដីទំហំ ........... ហិកតា នៅក្នុងអនុតំបន់ ................................................................... (ស្នើភ្ជាប់ឯកសារពាក់ព័ន្ធ)
    - ទំហំដីកាត់ឆ្វៀលតាមបញ្ជា (០១បប និងកាត់ឆ្វៀលក្នុងអំឡុងពេលចុះបញ្ជីដីរដ្ឋ) សរុប **៦០៧,២១ ហិកតា** នៅក្នុងអនុតំបន់ ១ ដល់ ៦
    - ទំហំដីកាត់ឆ្វៀលចេញនៅភាគខាងជើងសម្បទានដីសេដ្ឋកិច្ច ៣០៨,៩៤ ហិកតា ក្នុងអនុតំបន់ទី១០
    - ប៉ះពាល់ជាមួយសម្បទានដីសេដ្ឋកិច្ចរបស់ LYP ទំហំ ១២០,៧០ ហិកតា ក្នុងអនុតំបន់ទី ៨
    - តំបន់យកគ្រួសក្រហម ២១៩,៧៤ ហិកតា ក្នុងអនុតំបន់ទី៧
    - សម្បទានសង្គមកិច្ច ១៩០,៧៩ ហិកតា ក្នុងអនុតំបន់ទី៧
    - តំបន់ការពារប្រភពទឹក ៤៧៦,៤៥ ហិកតា ក្នុងអនុតំបន់ទី ១ ដល់ ១០

ទំហំដីនៅសល់ជាក់ស្តែងក្នុងតំបន់សម្បទានទំហំ **៧៨៩៦,១១** ហិកតា (ជូនភ្ជាប់វិញ្ញាបនប័ត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច ១៧ប័ណ្ណ)

- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិ ៖ មាន ☐ គ្មាន ☒ ផ្ទៃដីទំហំ ........... ហិកតា នៅក្នុងអនុតំបន់.................................................. (ស្នើភ្ជាប់ឯកសារពាក់ព័ន្ធ)
- តំបន់ធ្វើអាជីវកម្មរ៉ែ ៖ មាន ☐ គ្មាន ☒ ផ្ទៃដីទំហំ ........... ហិកតា នៅក្នុងអនុតំបន់.................................................. (ស្នើភ្ជាប់ឯកសារពាក់ព័ន្ធ)
- តាមលិខិតលេខ ០៥ ប្រកព ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី៖ មាន ☐ ឬ គ្មាន ☒ ផ្ទៃដីទំហំ ........... ហិកតា នៅក្នុងអនុតំបន់ .............
- ការកាត់ផ្សេងៗបម្រើឲ្យប្រយោជន៍សាធារណៈ (ផ្លូវ វារីអគ្គីសនី គ្រឹះបង្គោលអគ្គីសនី...)៖ មាន ☐ ឬ គ្មាន ☒ ផ្ទៃដីទំហំ ........... ហិកតា នៅក្នុងអនុតំបន់ .......................

បញ្ជាក់៖ បើតំបន់សម្បទានដីសេដ្ឋកិច្ចមានពាក់ព័ន្ធនឹងករណីកាត់ឆ្វៀលណាមួយ ស្នើភ្ជាប់ឯកសារពាក់ព័ន្ធ និងផែនទីទីតាំងកាត់ឆ្វៀល។

**ផ្នែកទី-V៖ ការអនុវត្តការណែនាំរបស់ក្រសួង រាជរដ្ឋាភិបាល**

១-ការណែនាំរបស់ក្រសួង

| ល.រ | លិខិតលេខ | ខ្លឹមសារ | លទ្ធផលអនុវត្តន៍បានតាមការណែនាំរបស់ក្រសួង |
|---|---|---|---|
| | | | |

២-លទ្ធផលអនុវត្តន៍ខ្លឹមសារ សជណ តាមរបាយការណ៍របស់គណៈកម្មការអន្តរក្រសួង⁽⁹⁾៖

| ល.រ | លិខិតលេខ សជណ | ខ្លឹមសារសម្រេចរបស់ សជណ | លទ្ធផលអនុវត្តន៍បានតាមខ្លឹមសារ សជណ |
|---|---|---|---|
| | | | |

**ផ្នែកទី-VI៖ ការវាយតម្លៃការអនុវត្តគម្រោង៖**

- តាមពេលកំណត់ ៖ □ (ស្នើបញ្ជាក់មូលហេតុ និងបញ្ហា)..........
- មុនពេលកំណត់ ៖ □ (ស្នើបញ្ជាក់មូលហេតុ និងបញ្ហា)..........
- យឺតជាងពេលកំណត់ ៖ □ (ស្នើបញ្ជាក់មូលហេតុ និងបញ្ហា)..........
- មិនបានចាប់ផ្តើម ៖ □ (ស្នើបញ្ជាក់មូលហេតុ និងបញ្ហា)..........
- ត្រូវតាមផែនការមេ ៖ ☒ (ស្នើបញ្ជាក់មូលហេតុ និងបញ្ហា) **ប៉ុន្តែដោយនៅឆ្នាំ២០២១ មិនមានការអភិវឌ្ឍន៍ចម្ការឈើ និងឆ្នាំ២០២២មានការអភិវឌ្ឍន៍ចម្ការឈើពាណិជ្ជកម្មបន្តិចបន្តួច ដែលធ្វើឱ្យការអនុវត្តមានការយឺតបន្តិចបន្តួច បើធៀបទៅនឹងផែនការមេ។** ..........
- មិនតាមផែនការមេ ៖ □ (ស្នើបញ្ជាក់មូលហេតុ និងបញ្ហា)
- បានបញ្ចប់គម្រោង ៖ □ (ស្នើបញ្ជាក់មូលហេតុ និងបញ្ហា)..........
- ចំណុចបំពេញបាន ៖ (ស្នើបញ្ជាក់មូលហេតុ និងបញ្ហា)..........
- ចំណុចខ្វះខាត / មិនបំពេញបាន ៖ (ស្នើបញ្ជាក់មូលហេតុ និងបញ្ហា)..........

**ផ្នែកទី-VII៖ បញ្ហាផ្សេងៗ ការប្រឈម និងសំណូមពររបស់ក្រុមហ៊ុន**

១- វឌ្ឍនភាពការងារដែលក្រុមហ៊ុនមិនបានរៀបរាប់ខាងលើ

- ចូលរួមសហការ និងចុះល្បាតក្នុងតំបន់ស្ថានីយស្តារព្រៃឈើជាមួយក្រុមមន្រ្តីប្រចាំការរបស់រដ្ឋបាលព្រៃឈើ។
- ល្បាតការពារចម្ការពីបទល្មើសនានាមានដូចជាការលួចកាប់ឈើធម្មជាតិនៅតាមសម្បទានដីសេដ្ឋកិច្ច អន្ទាក់សត្វ និងការប្រមូលផលអនុផល ព្រៃឈើផ្សេងទៀត។
- ថែទាំកូនឈើប្រេងខ្យល់ កូនឈើធម្មជាតិ នៅថ្នាលបណ្តុះកូនឈើ
- បន្តធ្វើការកំណត់ផ្លូវក្នុងសម្បទានដីសេដ្ឋកិច្ចដែលបានហូរច្រោះ និងខូចខាត ដើម្បីរៀបចំផែនការជួសជុលនារដូវប្រាំងខាងមុខនេះ។
- បន្តខិតខំប្រឹងប្រែងដោះស្រាយបញ្ហាដីធ្លីដែលកើតមានត្រួតព្រំសម្បទានដីសេដ្ឋកិច្ច និងអូរការពារប្រភពទឹក។

– ធ្វើការដាំស្តារតំបន់ការពារប្រភពទឹក ដែលបានដោះស្រាយបញ្ហាដីធ្លីរួចរាល់។

២- ផែនការអនុវត្តន៍បន្តរបស់ក្រុមហ៊ុន

(១)គណៈកម្មការអន្តរក្រសួង ដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានសេដ្ឋកិច្ច............................................................................................................................................

– សម្រាប់ឆ្នាំ២០២២ ក្រុមហ៊ុននឹងមិនធ្វើការអភិវឌ្ឍចម្ការឈើ ឬការដាំដុះទេ។
– ក្រុមហ៊ុនបន្តធ្វើការថែទាំចម្ការឈើ ដោយធ្វើរហាល។
– បន្តបណ្តុះកូនឈើនៅថ្នាលបណ្តុះសម្រាប់ឆ្នាំ ២០២៣។
– រៀបចំក្រុមការងារសម្រាប់រដូវកាលភ្លើងព្រៃ
– រៀបចំភ្លូវក្នុងចម្ការឈើ និងជួសជុលផ្លូវភ្លើងសម្រាប់រដូវភ្លើងឆេះព្រៃនាពេលខាងមុខនេះ។

៣- បញ្ហាប្រឈម

- បញ្ហាដីធ្លី
- បញ្ហាកាប់ឈើខុសច្បាប់សម្រាប់អុសឡ អុសស្នែរនៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច (តំបន់ការពារអូរ និងដីដែលត្រូវដាំដុះទៅអនាគត)។
- បញ្ហាលួច និងបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន រួមមាន៖ កាត់របង, បំផ្លាញស្លាកបដា កាប់បំផ្លាញឈើពាណិជ្ជកម្ម។
- ទទួលបានការគម្រាមគំហែងពីសំណាក់ជនល្មើសដែលលួចកាប់ឈើធ្វើអុសឡ អុសស្នែរ ទៅដល់បុគ្គលិករបស់ក្រុមហ៊ុន ចំពោះការពង្រឹងការអនុវត្តច្បាប់ថ្មីៗនេះដែលមានការចូលរួមពីមន្ត្រីរដ្ឋបាលព្រៃឈើ លើបញ្ហាកាប់ឈើខុសច្បាប់ទាំងក្នុងសម្បទានដីសេដ្ឋកិច្ច និងក្នុងតំបន់ស្ថានីយ។

៤- សំណូមពរ

- ស្នើសុំឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តដាក់មន្ត្រីប្រចាំការដើម្បីបង្ក្រាបបទល្មើសដែលកើតមាននៅក្នុងតំបន់ស្ថានីយស្តារព្រៃឈើឡើងវិញ បើទោះជាស្ថានភាពនៃការកាប់ឈើខុសច្បាប់បានធូរស្រាលបន្តិច។
- ស្នើសុំឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមានវិធានការផ្លូវច្បាប់តឹងរឹងបំផុតចំពោះអ្នកបរបាញ់ ដាក់អន្ទាក់សត្វព្រៃ និងអ្នកដុតបំផ្លាញព្រៃឈើ ឬចម្ការឈើដាំរបស់ក្រុមហ៊ុនដោយចេតនា។
- ស្នើសុំឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ត និងពង្រឹងការចុះណែនាំអប់រំប្រជាពលរដ្ឋពីបញ្ហាបង្ករភ្លើងឆេះព្រៃ វាលស្មៅ ឬព្រៃតាមទ្រនាប់អូរ ដើម្បីជាប្រយោជន៍ចំណីសត្វពាហនៈឬគោលបំណងផ្សេងដែលបង្កជាហានិភ័យធ្ងន់ធ្ងរ។
- ស្នើសុំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជួយបន្តតាមដានឱ្យនភាពនៃលិខិតដែលក្រុមហ៊ុនបានដាក់ជូនឯក ឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអំពីបញ្ហាដីធ្លី ទៅតាមការស្នើសុំក្នុងខ្លឹមសារលិខិតដែលបានដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីថ្ងៃទី២០ កក្កដា ឆ្នាំ២០២១។

ថ្ងៃ ...................... ខែ .................... ឆ្នាំ ............. ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅ .................. ថ្ងៃទី ............ ខែ ................ ឆ្នាំ២០២២

**ប្រធានប្រតិបត្តិក្រុមហ៊ុន**